# The Safe Migration Project

# ការចាប់ផ្តើមចូលរៀននៅសាលាមធ្យមសិក្សា

## ត្រូវប្រាកដថាកូនរបស់អ្នកធ្វើដំណើរដោយសុវត្ថិភាពទៅសាលាមធ្យមសិក្សាជាមួយនឹងដំបូន្មានសំខាន់ៗទាំងនេះ។

### បន្ថយល្បឿននៅពេលបើកបរ

កុមារ និងមនុស្សជំទង់មិនតែងតែសង្កេតឃើញប្រភពគ្រោះថ្នាក់ជានិច្ចនោះទេនៅពេលប្រើប្រាស់ផ្លូវថ្នល់។ នេះមានន័យថាកុមារមានហានិភ័យខ្ពស់ជាងនៅលើ នឹងជុំវិញផ្លូវថ្នល់។

- ត្រូវបន្ថយល្បឿន និងយកចិត្តទុកដាក់បន្ថែមនៅពេលបើកបរតំបន់ជុំវិញសាលារៀនដើម្បីការពារមនុស្សវ័យក្មេង។
- ការបើកបរក្រោមល្បឿនកំណត់ដែលមានស្លាកសញ្ញាជួយឱ្យកុមារ និងបរិស្ថានជុំវិញសាលារៀនកាន់តែមានសុវត្ថិភាព។

### រៀបចំផែនការធ្វើដំណើរតាមផ្លូវថ្នល់ដែលមានសុវត្ថិភាពបំផុត

មិនថាដើរ ឬជិះទៅសាលារៀនទេ វាសំខាន់ដែលអ្នកត្រូវ៖

- ចំណាយពេលជាមួយកូនរបស់អ្នកក្នុងការរៀបចំផែនការធ្វើដំណើរតាមផ្លូវដែលមានសុវត្ថិភាពបំផុត -**ផ្លូវដែលលឿនជាងគេបំផុតមិនមែនតែងតែជាផ្លូវដែលមានសុវត្ថិភាពបំផុតនោះទេ**
- ធ្វើដំណើរតាមផ្លូវជាមួយគ្នាមុនឆ្នាំសិក្សាចាប់ផ្តើម ដើម្បីឱ្យបានស្គាល់ផ្លូវកាន់តែច្បាស់ និងធានាថាមានសុវត្ថិភាព
- ជួយកូនរបស់អ្នករៀបចំផែនការដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមាន ដូចជាផ្លូវមមាញឹក និងផ្លូវល្បឿនលឿន និងផ្លូវប្រសព្វដ៏ស្មុគស្មាញនៅតាមផ្លូវរបស់ពួកគេទៅសាលារៀន
- រៀបចំផែនការធ្វើដំណើរតាមផ្លូវថ្នល់ដែលមានល្បឿនកំណត់ទាប (យកល្អល្បឿនកំណត់ត្រឹម 40 គីឡូម៉ែត្រក្នុងមួយម៉ោង ឬតិចជាងនេះ)។

### លើកទឹកចិត្តការដើរដោយសុវត្ថិភាព

ការដើរគឺជាទម្រង់ដ៏អស្ចារ្យមួយនៃការធ្វើដំណើរសកម្មទៅសាលារៀន ពីព្រោះវាលើកកម្ពស់សុខភាព និងសុខុមាលភាព ហើយវាល្អប្រសើរសម្រាប់បរិស្ថាន។ ប្រសិនបើដើរ៖

- លើកទឹកចិត្តកូនរបស់អ្នកកុំឱ្យមានការបែកអារម្មណ៍ដូចជាការប្រើទូរសព្ទចល័ត ជាពិសេសនៅពេលកំពុងដើរឆ្លងផ្លូវថ្នល់
- រម្លឹកកូនរបស់អ្នកឱ្យដើរឆ្លងផ្លូវនៅលើគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់ មានភ្លើងសញ្ញាចរាចរណ៍សម្រាប់ថ្មើរជើងឆ្លងកាត់ កន្លែងថ្មើរជើងអាចឈប់បាន និងទីតាំងនានាដែលអ្នកបើកបរអាចមើលឃើញពួកគេច្បាស់។

### ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈដោយវ័យឆ្លាត

ការធ្វើដំណើរទៅសាលាមធ្យមសិក្សាតែងតែពាក់ព័ន្ធនឹងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ។ ដើម្បីធ្វើដូច្នេះដោយសុវត្ថិភាព៖

- រៀបចំផែនការ និងហាត់ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈជាមួយកូនរបស់អ្នកមុនឆ្នាំសិក្សាចាប់ផ្តើម
- នៅពេលកំពុងរង់ចាំរថភ្លើង រថយន្តក្រុង និងរថត្រែម ចូរលើកទឹកចិត្តកូនរបស់អ្នកឱ្យឈរនៅពីខាងក្រោយគំនូសពណ៌លឿងនៅលើកន្លែងជិះរថភ្លើង និងឆ្ងាយពីផ្លូវនៅចំណតរថយន្តក្រុង ឬរថត្រែម
- រម្លឹកកូនរបស់អ្នកឱ្យចុះពីលើរថយន្តក្រុង និងរថត្រែមទៅកាន់ផ្លូវដើរដែលនៅជិតបំផុត - ហាមដើរឆ្លងផ្លូវពីខាងក្រោយរថយន្តក្រុង ឬរថត្រែម

TAC

ROAD SAFETY EDUCATION VICTORIA

# The Safe Migration Project
## ការចាប់ផ្តើមចូលរៀននៅសាលាមធ្យមសិក្សា



## លើកទឹកចិត្តការជិះកង់ដោយសុវត្ថិភាព

ការជិះកង់ជាជម្រើសធ្វើដំណើរដ៏សកម្មល្អមួយក្នុងការធ្វើដំណើរទៅសាលារៀន។ ដើម្បីជួយកូនរបស់អ្នកឱ្យជិះកង់ទៅសាលារៀនដោយសុវត្ថិភាព៖

- ជួយពួកគេឱ្យរៀបចំផែនការធ្វើដំណើរតាមផ្លូវដែលមានសុវត្ថិភាពបំផុត ដោយផ្តល់អាទិភាពដល់កង់ និងផ្លូវប្រើរួមគ្នា ប្រសិនបើមាន
- ពេលណាគ្មានផ្លូវសម្រាប់កង់ និងផ្លូវប្រើរួមគ្នាទេ ហើយកុមារមានអារម្មណ៍សុខស្រួល ចូរជ្រើសរើសផ្លូវមានល្បឿនកំណត់ទាបដែលមានគន្លងសម្រាប់កង់ជិះ និងហេដ្ឋារចនាសម្ព័ន្ធពិសេស
- កង់ត្រូវតែមានកណ្តឹង ហ្វ្រាំង និងចំណាំងផ្លាតខាងក្រោយ
- ត្រូវធានាថាកូនរបស់អ្នកដឹងថាពួកគេត្រូវពាក់មួកសុវត្ថិភាពនៅពេលជិះកង់ - **មួកសុវត្ថិភាពកាត់បន្ថយហានិភ័យការរងរបួសក្បាលរហូតដល់ទៅ 74%**[1]
- មួកសុវត្ថិភាពត្រូវបំពេញតាមស្តង់ដាអូស្ត្រាលី និងបំពាក់ត្រូវសមនឹងក្បាលដើម្បីផ្តល់ការការពារត្រឹមត្រូវ។

អ្វីដែលសំខាន់ជាងនេះទៅទៀត ថាកូនរបស់អ្នកដឹង៖

- ច្បាប់តម្រូវឱ្យពាក់មួកសុវត្ថិភាព (និងភ្ជាប់ខ្សែ) នៅពេលជិះកង់ - **ការមិនធ្វើដូចនេះនឹងរងការផាកពិន័យ $261**
- នៅរដ្ឋវិកថូរៀ កុមារអាយុក្រោម 16ឆ្នាំមិនអាចជិះកង់រុញអេឡិចត្រូនិក (e-scooter) បានទេ ពីព្រោះវាខុសច្បាប់ និងមានគ្រោះថ្នាក់ - **ពួកគេអាចរងការផាកពិន័យ $314 ប្រសិនបើធ្វើដូចនេះ**
- មានច្បាប់ជាច្រើនដែលគ្រប់គ្រងនៅពេលណា និងរបៀបប្រើកង់រុញអេឡិចត្រូនិក ហើយការបំពានច្បាប់អាចរងការផាកពិន័យធ្ងន់ធ្ងរ។

## ត្រូវបើកបរ និងចតដោយសុវត្ថិភាព ប្រសិនបើបើកបរទៅសាលារៀន

ប្រសិនបើអ្នកបើករថយន្តជូនកូនរបស់អ្នកទៅសាលារៀន វាសំខាន់ដែលត្រូវ៖

- ធានាថាអ្នកដំណើរគ្រប់រូបពាក់ខ្សែក្រវាត់សុវត្ថិភាព ប្រើកៅអីសុវត្ថិភាពសម្រាប់កុមារ ឬកៅអីបន្ទុប ដើម្បីរក្សាសុវត្ថិភាព ហើយអនុលោមតាមច្បាប់
- ប្រើទីតាំងសម្រាប់ទម្លាក់ចុះ និងចតដោយសុវត្ថិភាពនៅពេលទម្លាក់កូនចុះ និងមកទទួលកូន។ ប្រសិនបើអាច ត្រូវចតឱ្យឆ្ងាយបន្តិចពីច្រកទ្វារសាលាដើម្បីជួយកាត់បន្ថយការកកស្ទះ និងហានិភ័យនានា

### ព័ត៌មានបន្ថែម

ដើម្បីទទួលបានព័ត៌មានជាភាសាណាណាមួយ សូមទូរសព្ទទៅសេវាកម្មជាតិបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS National) តាមលេខ 131 450 រួចស្នើសុំអ្នកបកប្រែផ្ទាល់មាត់

**ដំបូន្មានក្នុងការប្រើមធ្យោបាយដឹកជញ្ជូនសាធារណៈ៖**

www.ptv.vic.gov.au/more/travelling-on-the-network/travelling-safely/

**សុវត្ថិភាពសម្រាប់អ្នកជិះកង់៖**

www.transport.vic.gov.au/road-rules-and-safety/bicycles/cycling-with-children

**ច្បាប់ផ្លូវថ្នល់សម្រាប់កង់រុញអេឡិចត្រូនិក៖**

https://www.tac.vic.gov.au/road-safety/road-users/e-scooters

**កម្មវិធីអប់រំអ្នកជិះកង់សម្រាប់សាលារៀន៖**

www.roadsafetyeducation.vic.gov.au/educational-resources/programs/bike-ed-new

**ការអប់រំស្តីពីសុវត្ថិភាពតាមផ្លូវថ្នល់រដ្ឋវិកថូរៀ៖**

www.roadsafetyeducation.vic.gov.au

1 Bambach, M. R., Mitchell, R. J., Grzebieta, R. H., Olivier, J. The effectiveness of helmets in bicycle collisions with motor vehicles: A case-control study. Accident Analysis and Prevention, Issue 53, 2013.

TAC

ROAD SAFETY EDUCATION VICTORIA